ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៧ សហវ.ទស

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**កម្មវត្ថុ:** ការលើកសំណើសុំប្រើប្រាស់ថវិកាពីមូលនិធិបដិភាគជប៉ុន សម្រាប់គម្រោងប្រព័ន្ធធារាសាស្ត្រម្កាក់ ស្រុកជីក្រែង ខេត្តសៀមរាប ។

**យោង:** -កំណត់ទូតលេខ 492 AJ/ECO ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១០ របស់ស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ។

-លិខិតលេខ ១៤៥៦ ធទឧ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា តាមការអនុម័តរបស់រដ្ឋាភិបាលជប៉ុនស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់ថវិកាពីមូលនិធិបដិភាគជប៉ុន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធានាចំណាយជូនក្រសួងធនធានទឹក និងឧតុនិយម ជាប្រាក់រៀលសមមូលនឹងចំនួន US$ 3,081,096.00 សម្រាប់គម្រោងប្រព័ន្ធធារាសាស្ត្រម្កាក់ ស្រុកជីក្រែង ខេត្តសៀមរាប ។ ទន្ទឹមនឹងនេះ អនុលោមបទដ្ឋានអនុវត្តរបស់ជប៉ុន សូមក្រសួងធនធានទឹក និងឧតុនិយមធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរស្តីពីការអនុវត្តគម្រោងដូចមានគំរូជូនភ្ជាប់ ក្រោយពីគម្រោងត្រូវបានបញ្ចប់ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីក្រសួងធ្វើរបាយការណ៍បន្តជូនទៅភាគីជប៉ុន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងមានវិធានការ តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ជ.រដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

- ឯកសារ-កាលប្បវត្តិ